ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ:..................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ «ការបន្តអភិវឌ្ឍនិងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិ» របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សម្រាប់ការិយបរិច្ឆេទ២០២៤



## ការិយបរិច្ឆេទ២០២៤

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA

Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900

E-mail: naakh@naa.gov.kh website: www.naa.gov.kh

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ «ការបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិ» របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សម្រាប់ការិយបរិច្ឆេទ២០២៤

## របាយការណ៍សង្ខេប

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលត្រូវបានបង្កើតដោយព្រះរាជក្រមលេខនស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៅព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ និងអនុក្រឹត្យលេខ៥៦ អនក្រ.បកចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

វិស័យអាកាសចរណ៍ស៊ីវិលគឺជាឧស្សាហកម្មដែលកំពុងតែរីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងតំបន់ និងសកលលោក។ វិស័យនេះ ក៏ត្រូវបានចាត់ទុកថា ជាកត្តាយុទ្ធសាស្ត្រនៃផលិតកម្ម និងជាស្នូលនៃដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ បច្ចុប្បន្ននេះ វិស័យអាកាសចរណ៍ស៊ីវិលគឺជាវិស័យមួយដែលកំពុងមានភាពទាក់ទាញ និងរីកចម្រើនប្រកបដោយសក្តានុពលព្រមទាំងជាផ្នែកដ៏សំខាន់មួយមិនអាចខ្វះបានក្នុងការចូលរួមជួយជំរុញកំណើនសេដ្ឋកិច្ចសកលលោក តាមរយៈការជួយសម្រួលដល់លំហូរពាណិជ្ជកម្មអន្តរជាតិ ទេសចរណ៍ វិនិយោគទុនអន្តរជាតិ និងជួយតភ្ជាប់ប្រជាជនពីទ្វីបមួយទៅកាន់ទ្វីបមួយទៀតនៅទូទាំងសកលលោក។ វិស័យអាកាសចរណ៍ស៊ីវិលត្រូវពឹងផ្អែកលើការធ្វើដំណើរនៃភ្ញៀវទេសចរ ស្របពេលដែលភ្ញៀវទេសចរ ក៏ត្រូវអាស្រ័យលើការដឹកជញ្ជូនតាមផ្លូវអាកាសផងដែរ។

នៅក្នុងសម័យប្រជុំប្រចាំឆ្នាំរបស់មហាសន្និបាតអង្គការសហប្រជាជាតិក្នុងខែកញ្ញា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជារួមជាមួយប្រទេសជាសមាជិក អង្គការសហប្រជាជាតិ (អ.ស.ប) បានអនុម័តរបៀបវារៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (គ.អ.ច) ២០១៦-២០៣០។ បន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តខិតខំធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសាកលឱ្យស្របតាមបរិការណ៍កម្ពុជាដែលហៅថាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក)។ គោលដៅទាំងនេះ ក៏ត្រូវបានធ្វើសមាហរណកម្មនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យនៅគ្រប់យុទ្ធសាស្ត្រទី៥ ការអភិវឌ្ឍហេដ្ឋានរចនាសម្ព័ន្ធអាកាសយានដ្ឋានដែលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានត្រូវស្របទៅនឹងកំណើនអ្នកដំណើរតាមផ្លូវអាកាស និងមានគោលបំណងធ្វើឱ្យវិស័យអាកាសចរណ៍ស៊ីវិលឆ្លើយតបបានយ៉ាងល្អប្រសើរបំផុតចំពោះតម្រូវការនានារបស់អ្នកប្រើប្រាស់ដោយអភិវឌ្ឍអាកាសយានដ្ឋានស៊ីវិល និងជំរុញឱ្យមានការអភិវឌ្ឍក្នុងវិស័យការពារអ្នកប្រើប្រាស់មានអ្នកដំណើរតាមផ្លូវអាកាស និងការចុះចតអាកាសយានប្រកបដោយប្រសិទ្ធភាព។ ម៉្យាង

ទៀតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលក៏ជាសមាជិកនៃក្រុមខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាផងដែរ។

អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទសវនកម្ម «ការបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិ » របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលសម្រាប់ការិយបរិច្ឆេទ២០២៤ និងឆ្នាំពាក់ព័ន្ធក្នុងគោលបំណងវាយតម្លៃលើដំណើរការរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលក្នុងការអនុវត្តមូលដ្ឋាននីយកម្ម គ.អ.ច.ក ការអនុវត្តផែនការយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព សូចនាករសម្រាប់ការបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិ និងយន្តការដើម្បីតាមដានត្រួតពិនិត្យឡើងវិញ និងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្ត គ.អ.ច.ក ទី៩ ចំណុច៩.១.២ និងចំណុច៩.១.៣។

ក្រោយពីបានបញ្ចប់ការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលបានខិតខំយកចិត្តទុកដាក់ក្នុងការអនុវត្តការងាររបស់ខ្លួនស្របតាមគោលដៅទី៩ ចំណុចដៅ៩.១.២ និងចំណុចដៅ៩.១.៣ ហើយថែមទាំងបានចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព សូចនាករ និងយន្តការដើម្បីតាមដានត្រួតពិនិត្យឡើងវិញ និងការរាយការណ៍អំពីវឌ្ឍនភាពដើម្បីឆ្លើយតបគោលបំណង និងគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។ល។ ទន្ទឹមនឹងនេះ កិច្ចប្រតិបត្តិការបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា៖

១. ដំណើរការនៃការធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជានៅមានកម្រិត៖ ការអនុវត្តមូលដ្ឋាននីយកម្មនៅមិនទាន់ឆ្លើយតបវត្ថុបំណង ចំណុចដៅដូចជាកំណើនអ្នកដំណើរតាមផ្លូវអាកាសនៅមិនទាន់ឆ្លើយតបតាមសូចនាករចំណុចដៅ មន្ត្រីជំនាញបច្ចេកទេសនៅតម្រូវឱ្យមានការបណ្តុះបណ្តាលបន្ថែមដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃចំនួនក្រុមហ៊ុនអាកាសចរណ៍។ លិខិតបទដ្ឋានបច្ចេកទេសមួយចំនួននៅមានការខ្វះចន្លោះ និងមិនទាន់ធ្វើបច្ចុប្បន្នភាពដែលចាំបាច់ត្រូវឱ្យមានការរៀបចំ និងការកែសម្រួលឡើងវិញដើម្បីឆ្លើយតបនឹងអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) ហើយភាពប្រទាក់ក្រឡានៃការអនុវត្តរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការយុទ្ធសាស្ត្រថវិកាមិនទាន់មានសង្គតិភាព។

២. ការអនុវត្តផែនការសកម្មភាពនៅមានកម្រិតដូចជា៖ កង្វះខាតមន្ត្រីជំនាញមានបទពិសោធន៍សម្រាប់រៀបចំបទដ្ឋានបច្ចេកទេស បទប្បញ្ញត្តិគតិយុត្តមួយចំនួននៅមិនទាន់ស្របតាមស្តង់ដា ICAO បទដ្ឋានបច្ចេកទេសមួយចំនួននៅមិនទាន់ធ្វើសិក្ខាសាលាផ្សព្វផ្សាយដល់ក្រុមហ៊ុនអាកាសចរណ៍ ថវិកានៅមានកម្រិត ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅតាមអាកាសយានដ្ឋានជាតិនិងអន្តរជាតិនៅកើតមានចំណុចខ្វះខាតដូចជា៖ គំនូសសញ្ញាអ័ក្សផ្លូវរត់ត្រង់តំបន់ Touchdown មានសភាពរលុប បុគ្គលិកដែលអនុវត្តការងារត្រួតពិនិត្យតំបន់ចល័តអាកាសយានមិនទាន់ទទួលបានការហ្វឹកហ្វឺនស្តីពី GRF (Runway Condition Code) ។ សៀវភៅ Aerodrome Manual ទិន្នន័យមួយចំនួនមិនទាន់ទទួលបានការធ្វើបច្ចុប្បន្នភាព និងមួយចំនួនទៀតមានលក្ខណៈមិន

សុក្រឹត ហើយការត្រួតពិនិត្យភ្លើងបំភ្លឺបំពាក់លើឧបសគ្គមិនមាននៅក្នុងតារាងការងារត្រួតពិនិត្យភ្លើងបំភ្លឺ និងភ្លើងសញ្ញា។ល។

៣. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅមានកម្រិតដូចជា៖ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការប្រតិបត្តិប្រចាំឆ្នាំដូចជា៖ កង្វះខាតការតាមដានត្រួតពិនិត្យ និងវាយតម្លៃនៅកម្រិតធាតុចូល ធាតុចេញ និងលទ្ធផល។ ការមិនបានវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រឱ្យស្របតាមផែនការនៅឡើយ។

ឆ្លងតាមការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ "ការបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិ" នៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលសម្រាប់ការិយបរិច្ឆេទ២០២៤ ដោយបានពិនិត្យលើលទ្ធផលសវនកម្ម និងសេចក្តីសន្និដ្ឋានខាងលើ អាជ្ញាធរសវនកម្មជាតិ សូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

**១**. រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល គួរពង្រឹងការអនុវត្តមូលដ្ឋាននីយកម្ម និងការរៀបចំផែនការឱ្យមានសង្គតិភាពដើម្បីឆ្លើយតបវត្ថុបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឱ្យមានប្រសិទ្ធភាព។

**២**. រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលគួរជំរុញអង្គភាពក្រោមឱវាទ និងភាគីពាក់ព័ន្ធឲ្យពង្រឹងការអនុវត្តកម្មវិធី ផែនការសកម្មភាព និងសូចនាករឱ្យបានទាន់ពេលវេលាមានប្រសិទ្ធភាព។

**៣**. រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល គួរពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការយុទ្ធសាស្ត្រថវិកាដោយឈរលើគោលការណ៍ណែនាំដូចមានបង្ហាញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យក្នុងការឆ្លើយតបនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានឱ្យមានប្រសិទ្ធភាព។

ជាមួយគ្នានោះរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលក៏បានធ្វើការឆ្លើយបំភ្លឺ ការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការក្រោមប្រធានបទ "ការបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិ និងអន្តរជាតិ" នៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលសម្រាប់ការិយបរិច្ឆេទ២០២៤ដែលមានអត្ថន័យដូចខាងក្រោម៖

ការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិតេជោ (Techo International Airport – KTI) គឺជាគម្រោងហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ដ៏សំខាន់បំផុតមួយក្នុងប្រវត្តិសាស្ត្រអាកាសចរណ៍ស៊ីវិលរបស់ព្រះរាជាណាចក្រកម្ពុជា។ គម្រោងទំហំធំបែបនេះ ជាធម្មតាត្រូវពាក់ព័ន្ធនឹងដំណើរការស្មុគស្មាញជាច្រើនរួមមានការសាងសង់ ការផ្តល់វិញ្ញាបនបត្រ និងប្រតិបត្តិការដែលត្រូវអនុវត្តស្របតាមស្តង់ដាសុវត្ថិភាពអាកាសចរណ៍ស៊ីវិលជាតិ និងអន្តរជាតិ។ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលសូមស្វាគមន៍ និងទទួលយកនូវអនុសាសន៍ស្ថាបនាដែលមានគោលបំណងពង្រឹងអភិបាលកិច្ច

និងការត្រួតពិនិត្យ។ នៅពេលដូចគ្នានេះ ក៏មានសារៈសំខាន់ផងដែរ ដែលការកត់សម្គាល់សវនកម្មត្រូវបានបកស្រាយក្នុងក្របខណ្ឌត្រឹមត្រូវនៃបទប្បញ្ញត្តិអាកាសចរណ៍ និងអនុវត្តន៍អភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិ។ ដោយឡែករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល នឹងខិតខំអនុវត្តតាមអនុសាសន៍សវនកម្មដូចខាងក្រោម៖

- បន្តពង្រឹង និងលើកកម្ពស់ការអនុវត្តមូលដ្ឋាននីយកម្មក្នុងការរៀបចំផែនការឱ្យមានសង្គតិភាព ដើម្បីឆ្លើយតបវត្ថុបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឱ្យមានប្រសិទ្ធភាពស្របតាមបរិបថវិស័យអាកាសចរណ៍ស៊ីវិល។

- បន្តជំរុញពង្រឹង និងលើកកម្ពស់ការអនុវត្តកម្មវិធី ផែនការសកម្មភាព និងសូចនាករឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពស្របតាមមូលដ្ឋាននីយកម្មនៃផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

- បន្តពង្រឹង និងលើកកម្ពស់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យក្នុងការឆ្លើយតបនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានឱ្យមានប្រសិទ្ធភាព។

នៅក្នុងនោះដែររដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក៏នៅតែបន្តប្តេជ្ញាចិត្តយ៉ាងពេញលេញ និងធានាថាការអភិវឌ្ឍ និងប្រតិបត្តិការអាកាសយានដ្ឋានទាំងអស់នៅកម្ពុជានឹងនៅតែបន្តអនុលោមតាមស្តង់ដាសុវត្ថិភាពខ្ពស់ ការអនុលោមតាមបទប្បញ្ញត្តិ និងភាពល្អឥតខ្ចោះក្នុងប្រតិបត្តិការស្រប ICAO SARPS ARPE និងឧត្តមានុវត្តល្អបំផុតក្នុងវិស័យតាមអាកាសចរណ៍អន្តរជាតិ។

អាជ្ញាធរសវនកម្មជាតិបានឃើញការបំភ្លឺរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលរួចហើយ។ អាជ្ញាធរសវនកម្មជាតិនឹងតាមដានការអនុវត្តអនុសាសន៍សវនកម្មជាបន្តទៀត។